# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 91

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

## ផ្នែក ក

១. ឈ្មោះគម្រោង : ការបញ្រ្ជាបយេនឌ័រទាក់ទងនឹង ផលប៉ះពាល់ នៃ ការប្រែប្រួល អាកាសធាតុ និង គ្រោះមហន្តរាយ ក្នុង វិស័យអ

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/10/15 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 30/09/17 |

៣. ចំណាយគម្រោងសរុប $100,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងកិច្ចការនារី

RESPONSIBLE UNIT

អង្គភាពទទួលខុសត្រូវ

៥. ស្ថានភាពគម្រោង គម្រោងដែលបានបញ្ចប់

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងជំនួយបច្ចេកទេស

៧. ប្រភពហិរញ្ញប្បទាន៖ ជំនួយឥតសំណង

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្រ្តបញ្ចកោណ ជំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងនឹងផ្តល់ការគាំទ្រសមត្ថភាពដល់ GCCC / ក្រសួងកិច្ចការនារី ដើម្បីអនុវត្តន៍លើការវិភាគគោលនយោបាយ កស្តុតាងជាមូលដ្ឋាននៃការប្រែប្រួលអាកាសធាតុ និងការគស៊ូមតិ ដែលអាចអនុញ្ញាតឱ្យពួកគេអនុវត្តលើតួនាទីជា គំរូ នៃការបញ្រ្ជាបការប្រែប្រួលអាកាសធាតុទៅក្នុងវិស័យផ្សេងទៀត។ គម្រោងនេះ នឹងរួមចំណែកដល់ គោលដៅ ជាយុទ្ធសាស្រ្តនៃផែនការនារីរតនៈ IV "ដើម្បី លើកកម្ពស់ សមភាពយេនឌ័រនៅក្នុងដំណើរការ និង គោលលនយោបាយ ការអនុវត្តន៍ ដែលទាក់ទងទៅនឹងប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតងនិង ការគ្រប់គ្រងហានិភ័យ គ្រោះមហន្តរាយ នៅក្នុង ក្រសួង និងស្ថាប័ន នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីកាត់បន្ថយផលប៉ះពាល់ លើស្រ្តី និងស្រ្តីងាយរងគ្រោះ ដើម្បី រួមចំណែកដល់ កំណើនសេដ្ឋកិច្ច និងការ ទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍបៃតង»។ គម្រោងនេះមានលទ្ធផលចុងក្រោយចំនួនពីរ ដែលបានកំណត់ ដូចខាងក្រោម:

លទ្ធផលគម្រោងទី១៖ ការបញ្រ្ជាបយេនឌ័រលើផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយក្នុងកិច្ចតែងការបង្រៀន និងការបង្រៀន ការរៀនក្នុងកម្មវិធីសិក្សាថ្នាក់មធ្យមសិក្សា

លទ្ធផលគម្រោងទី២៖ បង្កើនសមត្ថភាពបន្សាំខ្លួន ស្រ្តីមេគ្រួសារ និងក្មេងស្រីតាមរយៈការសាកល្បង និងការផ្សព្វផ្សាយ ការយល់ដឹងពីយេនឌ័រ និងភាពឋៃឆ្លាតនៃការរៀបចំបរិស្ថានសាលារៀន ជាគម្រូ និងការអន្តរាគមន៍ ដើម្បីគាំទ្រការចូលរួមរបស់ពួកគាត់ក្នុងការរៀបចំផែនការនៅថ្នាក់ក្រោមជាតិ និងដំណើរការនៃការធ្វើសេចក្តីសម្រេច។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

មិនគាំទ្រ

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍនវិស័យឧស្សាហកម្មកម្ពុជាដែរឬទេ ?

១១. វិស័យ ( សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

ការបញ្ជ្រាបយេនឌ័រ | Gender mainstreaming

Gender mainstreaming

Gender mainstreaming

១២. ទីតាំងអនុវត្តគម្រោង ( ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង )

ស្វាយរៀង, កំពត, ស្ទឹងត្រែង, កំពង់ឆ្នាំង,

១៣. គោលបំណងរបស់គម្រោង ( ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង )

បង្កើនភាពធន់របស់សហគមន៍ តាមរយៈការបញ្ជ្រាបយេនឌ័រលើផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនិង គ្រោះមហន្តរាយ ទៅក្នុងកម្មវិធីសិក្សារបស់សាលា នៅក្នុងខេត្តចំនួន 4 គឺ ( កំពង់ឆ្នាំង កំពត ស្ទឹងត្រែង និង ស្វាយរៀង) ។

១៤. ការពិពណ៌នាអំពីគម្រោង ( ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង )

គម្រោងនេះនឹងត្រូវអនុវត្តន៍ទាំងនៅថ្នាក់ ជាតិ និងថ្នាក់ក្រោមជាតិ។ នៅថ្នាក់ជាតិ គម្រោងនឹងបង្កើតក្រុមការងារ បច្ចេកទេសរួមមួយ ដែលរួមមាន ក្រសួងកិច្ចការនារី / GCCC ក្រសួងបរិស្ថាន/ CCD ក្រសួងអប់រំ យុវជន និងកីឡា / DCD និងម្លប់បៃតង ដើម្បីគាំទ្រដល់ការរៀបចំការបញ្ជ្រាបគោលការណ៍ណែនាំស្តីពី ផលប៉ះពាល់ការប្រែប្រួល អាកាសធាតុ ទៅក្នុងកម្មវិធីសាលា។ នៅថ្នាក់ក្រោមជាតិ គ្រូអនុវិទ្យាល័យ និងសិស្ស ដែលមកពីសាលារៀន គោលដៅ នឹងទទួលបានចំណេះដឹងស្តីពី ការបន្សាំ ការប្រែប្រួលអាកាសធាតុ តាមរយៈវគ្គសិក្សា ដែលបាន បង្កើតឡើងថ្មី និងចូលរួម ចាប់ផ្តើមអនុវត្តន៍ ការបន្សាំនេះ នៅក្នុងសាលាគោលដៅ និងសហគមន៍ ។

១៥. យុត្តិកម្មលើគម្រោង ( បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស )

ប្រជាជនក្រីក្រ និងងាយរងគ្រោះ ជាពិសេសស្ត្រី ការធ្វើសេចក្តីសម្រេច និងសមត្ថភាពបន្សាំរបស់ពួកគាត់នៅមាន ភាពទន់ខ្សោយ និងមានកម្រិតខ្លាំងណាស់ ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ក្នុងន័យនេះស្ត្រី និង ក្មេងស្រី មានឱកាសតិចជាងមុន ក្នុងការទទួលបានការអប់រំ និងការបណ្តុះបណ្តាល ជាពិសេសការទទួលបាន ព័ត៌មានទាក់ទងនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ព្រមទាំងការផ្តល់សេវាសង្គមផ្សេងៗទៀត។មូលហេតុទាំងអស់នេះហើយបានជាស្ត្រីមានការយល់ដឹងតិច និងធ្វើសកម្មភាពយឺតយ៉ាវទាក់ទងនឹងផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ ។

១៦. ផលប្រយោជន៍របស់គម្រោង ( រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង )

- ថ្នាក់ជាតិ៖ មន្ត្រី១២០នាក់ មកពីក្រសួងកិច្ចការនារី ក្រសួងអប់រំ និងមន្ត្រីរដ្ឋាភិបាល បានទទួលវគ្គបណ្ដុះបណ្ដាល គ្រូបង្គោល ក្រោមប្រធានបទការបញ្ជ្រាបយេនឌ័រលើផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ។
- ថ្នាក់ក្រោមជាតិ៖ មន្ត្រី ៦០នាក់ មកពីមន្ទីរកិច្ចការនារី មន្ទីរអប់រំ និងការិយាល័យអប់រំ ខេត្តស្ទឹងត្រែង កំពត ស្វាយរៀង និងកំពង់ឆ្នាំង និងគ្រូបង្រៀនសាលាគោលដៅទាំង៤សាលា ត្រូវបានទទួលវគ្គបណ្ដុះបណ្ដាលពីគ្រូបង្គោល ស្ដីពីរបៀបនៃការបញ្ជ្រាបយេនឌ័រលើផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយទៅក្នុងកម្មវិធី សិក្សា របស់សាលា។
- សហគមន៍៖ យ៉ាងហោចណាស់ ស្ត្រីជាមេគ្រួសារ កុមារ ជាពិសេសក្មេងស្រី២០០នាក់ នឹងទទួលផលដោយផ្ទាល់ ពីគម្រោង ហើយក្នុងពេលជាមួយគ្នានេះដែរគម្រោងនឹងផ្ដល់នូវសកម្មភាពជាច្រើនទាក់ទងនឹងការលើកកម្ពស់ ជីវភាពគ្រួសារផងដែរ។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទានចាប់ផ្តើម**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

គ្រូបង្រៀនអនុវិទ្យាល័យ និងសិស្សមកពីសាលាគោលដៅនឹងយល់ដឹងពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការបង្កើតកម្មវិធីសិក្សាថ្មី និងចាប់ផ្តើមអនុវត្តន៍ ការបន្សាំ និងការកាត់បន្ថយ នៅក្នុងសាលាគោលដៅ និងសហគមន៍។ មុនពេលចាប់ផ្តើម បណ្តុះបណ្តាលគ្រូបង្គោលដល់គ្រូអនុវិទ្យាល័យ គម្រោងនឹង ធ្វើការវាយតម្លៃ ពីតម្រូវការរបស់ស្ត្រី បន្ទាប់មកផ្តល់ជំនាញនានាសម្រាប់លើកកម្ពស់ជីវភាពរស់នៅរបស់ពួកគាត់ នៅពេលដែល គម្រោងសាកល្បងនេះបានអនុវត្តន៍នៅក្នុងសាលា/សហគមន៍ទាំង៤។

១៩. ការប្រែប្រួល អាកាសធាតុ

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែល ទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
| --- | --- | --- |

២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយបានរាយការណ៍ថា ទឹកជំនន់ក្នុងឆ្នាំ២០១១ បានប៉ះពាល់ដល់ដី កសិកម្ម ប្រមាណ ៦៨៣,៩៩៨ ហិកតា ដោយចំណាយទឹកប្រាក់ប្រហែល៤៥១លានដុល្លារ ទៅលើការខាតបង់ លើវិស័យនានានៃសេដ្ឋកិច្ច។ មនុស្ស ២៥០ នាក់ បានស្លាប់ និងរងរបួស ដែលក្នុងនោះ មានជាង៥០% ជាស្ត្រី និងកុមារ។ យេនឌ័រនៅក្នុងការប្រែប្រួលអាកាសធាតុ មិនទាន់បានអនុវត្តន៍ទូលំទូលាយនៅក្នុងប្រទេសកម្ពុជា នៅឡើយទេ។ នៅថ្នាក់ខេត្ត ស្រុកឃុំ និងសាលារៀន មានការខ្វះខាតជំនាញ និងធនធាន ដែលវាជាឧបសគ្គ ក្នុងការគាំទ្រដល់សហគមន៍ ដើម្បីកំណត់ និងចាប់ផ្តើមអនុវត្តន៍យេនឌ័រក្នុងការប្រែប្រួលអាកាសធាតុ។ បច្ចុប្បន្ន មិនមានការគាំទ្រក្នុងការអនុវត្តណាមួយសម្រាប់ ភាពងាយរងគ្រោះ សមត្ថភាព វិភាគគ្រោះថ្នាក់ និងកំណត់ផែនទី គ្រោះថ្នាក់ នៅកម្រិត ( សហគមន៍) នោះទេ។ ក្រសួងកិច្ចការនារីបានបញ្ចូលផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួល អាកាសធាតុ (2013-2022) នៅក្នុងផែនការយុទ្ធសាស្ត្រនារីរតនៈIV (2014-2018) ។ យុទ្ធសាស្ត្រនេះ មានតួនាទី សំខាន់សម្រាប់ ក្រសួងកិច្ចការនារី ដើម្បីធានានូវការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីការប្រែប្រួលអាកាសធាតុ របស់ ក្រសួងពាក់ព័ន្ធ ដើម្បីធានាថា ភាពងាយរងគ្រោះ តម្រូវការ និង សំលេងរបស់ស្ត្រី និងបុរសត្រូវបានគេដឹងឮ។

២២. សមត្ថភាពអនុវត្តគម្រោង (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

ក្រសួងកិច្ចការនារីបានរៀបចំ និងផ្សព្វផ្សាយផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ(2013-2022) ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការអនុវត្តគោលនយោបាយឆ្លើយតបនឹងយេនឌ័រទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ។ វាមិនមែនជាយុទ្ធសាស្ត្រដាច់ដោយឡែកនោះទេ ប៉ុន្តែវាជាបញ្ហាអន្តរវិស័យ នឹងបាន ដាក់បញ្ចូលនៅក្នុងផែនការយុទ្ធសាស្ត្រ[illegible]ការប្រែប្រួលអាកាសធាតុកម្ពុជា (2014-2023) ផងដែរ [illegible] ទាំងផែនការយុទ្ធសាស្ត្រ[illegible]ប្រែប្រួលអាកាសធាតុតាមវិស័យរបស់ក្រសួងពាក់ព័ន្ធទៀតផង។

២៣. [illegible] បណ្តាល ឲ្យ[illegible]

គម្រោងការបញ្ជ្រាបយេនឌ័រទាក់ទងនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយរបស់ ក្រសួង កិច្ចការនារី បានអនុវត្តន៍នូវសកម្មភាពមួយចំនួនតាមពេលវេលា ដូចជា ទីប្រឹក្សាថ្នាក់ជាតិ និងកម្មវិធីសិក្សា ទីប្រឹក្សា ថ្នាក់ជាតិ ផ្នែកតាមដាន និងវាយតម្លៃ ការពិនិត្យឡើងវិញលើកម្មវិធីសិក្សា ក្របខ័ណ្ឌការងាររបស់ក្រុមការងារ បច្ចេកទេសរួម កិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេសរួម និងការអង្កេតជាមូលដ្ឋាន។

២៤. អាទិភាពរបស់គម្រោង (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

6

២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

ផ្តល់នូវដំណើរការគម្រោង និងសកម្មភាព សម្រាប់ការតាមដាន និង ត្រួតពិនិត្យដោយ NCSD និងធ្វើរបាយការណ៍ វឌ្ឍនភាពទាក់ទងទៅនឹងសកម្មភាពគម្រោង ដោយប្រធានគម្រោងការបញ្ជ្រាបយេនឌ័រ ទាក់ទងនឹងផលប៉ះពាល់ អាកាសធាតុ និងគ្រោះមហន្តរាយក្នុងវិស័យអប់រំ។

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2016 | | 2017 | 2018 | 2019 | 2020 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2018-2020 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 59.4 | 0.0 | 40.4 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 59.4 | 0.0 | 40.4 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 59.4 | 0.0 | 40.4 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2016 | | 2017 | 2018 | 2019 | 2020 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2018-2020 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | 59.4 | 0.0 | 40.4 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| Other | 59.4 | 0.0 | 40.4 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 59.4 | 0.0 | 40.4 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

បានឃើញ និង ឯកភាព

រដ្ឋមន្ត្រី

កាលបរិច្ឆេទ: